# តើហេតុអ្វីបានជាយួនចង់បោះបង្គោលព្រំដែនសាជាថ្មី?

ដោយ លី-ឌៀប ★ ថ្ងៃទី២១ វិច្ឆិកា ២០០៩

យើងពុំដែលមានការភ័យខ្លាចដោយលាក់បំពួនខ្លួន (l'anonymat) ម្តងណាឡើយ អំពីការប្រើសេរីភាពក្នុងការនិយាយស្តីជាសាធារណៈ (liberté de paroles en public) អំពីបញ្ហានយោបាយខ្មែរ ក៏ដូចជាបញ្ហាបូរណភាពទឹកដីខ្មែរដែរ ។ យើងនិយាយចេញមក ដើម្បីឲ្យបងប្អូនខ្មែរបានដឹង បានយល់ និងដើម្បីចាត់ការឲ្យទាន់ពេលវេលា មុនខូចខាតដល់ទីជំរៅ បុរបូតផុតពីដៃ ។ យើងដឹងយ៉ាងច្បាស់ប្រាកដណាស់ថា វាមុខជាមានអ្នកប្រឆាំងនឹងយើងខ្លះៗពុំខានឡើយ... ក៏ប៉ុន្តែកិច្ចការបែបនេះ វាត្រូវតែមាននរណាម្នាក់ទទួលរងការវាយប្រហារដែលនឹងកើតឡើងជាយថាហេតុ ។

នៅក្នុងរឿងចង់បានទឹកដីខ្មែរ ពុំមែនជារឿងទើបកើតឡើងថ្មីៗឥឡូវឥឡានេះឯណា តែជាផែនការដែលដក់ជាប់នៅក្នុងខួរក្បាលរបស់ថ្នាក់ដឹកនាំយួនរាប់សតវត្សរ៍ណាស់មកហើយ ។ ផែនការនេះបានហុចឆ្លងបន្តគ្នាពីមេយួនម្នាក់ទៅមេយួនម្នាក់ទៀត (ទោះបីយួនសេរី ក៏ដូចជាយួនយៀកកុង-យៀកមិញដែរ) ឲ្យសម្លឹងគ្មានពព្រិចភ្នែកងាកមកទិសខាងលិចជាប់ជានិច្ច ។ មូលហេតុនោះគឺ ទឹកដីរបស់ពួកគេនៅទិសខាងជើងសុទ្ធតែជាតំបន់ព្រៃភ្នំក្រំថ្ម ពុំអាចប្រកបរបរកសិកម្មបានទេ ហើយប្រជាពលរដ្ឋរបស់គេកាន់តែមានចំនួនច្រើនឡើងៗជារៀងរាល់ឆ្នាំ ។ ទឹកដីខ្មែរនៅក្នុងតំបន់ដីសណ្តរទន្លេមេគង្គ (Mékong Delta) គឺជាទឹកប្រាក់-ដីមាស ពោលគឺជាជង្រុកស្រូវដ៏សំខាន់ខ្លាំងណាស់អាចចិញ្ចឹមប្រជាពលរដ្ឋរបស់គេបានមួយនគរ ។ រួចបន្ទាប់មក ពួកគេត្រូវសម្លឹងទៅប្រទេសលាវ និងកម្ពុជាកណ្តាលថែមទៀត ។

ផែនការវាតយកទឹកដីនេះ យួនបានរៀបចំធ្វើមួយដំណាក់ការម្តងៗ ។ យើងបានរៀបរាប់រួចហើយ អំពីបារាំងពុះកាត់ទឹកដីខ្មែរឲ្យទៅស្តេចយួនបៅដាយនៅក្រោមរាជ្យស្តេចសីហនុ (ថ្ងៃទី៤ មិថុនា ឆ្នាំ១៩៤៩) ហើយនិងអំពីអំពើក្បត់ជាតិរបស់ស្តេចសីហនុហក់ទៅជួយយួន ដោយបានគៀងគរយួនចូលមកឈ្លានពានប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧០ រហូតដល់យួនខ្ញីដៃគាត់ជាមួយនិងពួកខ្មែរក្រហម ធ្វើការកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរស្ទើរអស់មួយនគរ ដើម្បីទុកដីឲ្យទំនេរសំរាប់យួនហូរចូលមកតាំងទីលំនៅ និងប្រកបមុខរបររកស៊ីជំនួស ។ តាមការពិតស្តេចសីហនុគាត់មិនដែលស្រឡាញ់និងការពារខ្មែរម្តងណាទេ គឺគាត់ពិតជួយយួនឲ្យរួមគ្នាតែមួយ ដើម្បីមានកម្លាំងកាន់តែខ្លាំងក្លា ទំពារក្បាលខ្មែរឮគ្រូបៗទេតើ (!!) ។

លើកនេះ យើងនិងលើកឡើងអំពី តើហេតុអ្វីបានជាយួនត្រូវការចង់បោះបង្គោលព្រំដែនសាជាថ្មី ? ។ ទង្វើនេះបង្កើតជាសំនួរភ្លាមថា ៖ បើអញ្ចឹងវាមានតែបង្គោលព្រំដែនចាស់មិនត្រឹមត្រូវ ?? ឬមួយក៏គ្មានបង្គោលព្រំដែនពិតប្រាកដ ?? ។ ចុះដែលមេពួកយួនបានសន្យាហើយសន្យាទៀតស្ទើរសឹកបបូរមាត់ ថាគោរពបូរណភាពទឹកដីខ្មែរនោះ តើគោរពនៅត្រង់កន្លែងណាទៅ ?? តើគោរពនៅត្រង់កន្លែងដែលពួកខ្លួនគិតថាចង់ឲ្យគោរព ឬយ៉ាងដូចម្តេច ?? ។

គ្មានចម្លើយទៅនឹងសំនួរទាំងអស់នេះទាល់តែសោះ ។ គឺរហូតមកទល់ក្រោយពេលស្តេចសីហនុនិងពួកខ្មែរក្រហមសម្លាប់ខ្មែរស្ទើរស្លាត់នគរ ពោលគឺក្រោយពេលកងទ័ពយួនបោះពួយសំរុកចូលឈ្លានពានស្រុកខ្មែរជាលើកទី២នៅចុងឆ្នាំ១៩៧៨ (ឈ្លានពាននៅលើកទី១ឆ្នាំ១៩៧០ ស្តេចសីហនុជាអ្នកបបួល) ហើយយកប្រទេសខ្មែរជាចំណុះអាណានិគមរបស់ខ្លួនជាង១ទសវត្សរ៍ ដែលដល់ពេលក្រោយមកស្តេចសីហនុបានអុំងកងអបអរសាទរ «ថ្ងៃជ័យជំនះ៧ មករា ១៩៧៩», ផែនការវាតយកទឹកដីខ្មែរក៏ចាប់ផុសអណ្តែតត្រាមកលើផ្ទៃទឹក ។ នេះយើងមិននិយាយដល់អំពើក្បត់របស់ស្តេចសីហនុចំពោះពួកកងទ័ពជាតិនិយមសីហនុ ដែលបាននាំគ្នាតស៊ូទាំងដី ហើយស្លាប់គរជើងគ្នាស្អុយព្រៃនៅតាមទល់ដែននោះផងទេ ។

ពួកយួនបានបង្កើតសន្ធិសញ្ញាមួយចំនួនតម្រូវឲ្យពួកអាយ៉ងគាំទ្រ (សន្ធិសញ្ញាឆ្នាំ១៩៧៩, ១៩៨២, ១៩៨៣ និង១៩៨៥) ដែលសុទ្ធជាសន្ធិសញ្ញាឈ្លានពានលេបយកទឹកដីខ្មែរ ។ ដើម្បីឲ្យសន្ធិសញ្ញាទាំងអស់នេះក្លាយជា «ផ្លូវការ» យួនចាប់រៀបចំគំពេងការដូចតទៅ ៖ ទី១- ធ្វើយ៉ាងណាឲ្យពួកអាយ៉ងដែលវាលើកបន្តុប ក្លាយទៅជារដ្ឋាភិបាលស្របច្បាប់ និងមានការទទួលស្គាល់ជាអន្តរជាតិ ជាពិសេសឲ្យបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ។ ទី២- យួនមិនមែនចង់បានត្រឹមតែពួកអាយ៉ងប៉ុណ្ណោះទេ ដែលទទួលស្គាល់សន្ធិសញ្ញារបស់វា គឺវាចង់ឲ្យស្តេចស្រុកខ្មែររួមចំណែកទទួលស្គាល់ផងដែរ ។

ម្ល៉ោះហើយ ជាដំបូងគេឃើញយួននិងពួកអាយ៉ងរំកិលខ្លួនចូលទៅចែចូវស្តេចសីហនុនៅប្រទេសបារាំង (ទីក្រុង Fère-en-Tardenois) ដើម្បីឲ្យគាត់យល់ព្រមវិលត្រឡប់ចូលស្រុកខ្មែរវិញ ដោយសន្យាថានឹងលើកគាត់ឲ្យឡើងសោយរាជ្យជាលើកទី២។ ប្រការបែបនេះយួននិងពួកខ្មែរក្រហមធ្លាប់បានធ្វើម្តងរួចមកហើយ នៅពេលជ័យជំនះលើរបបសាធារណរដ្ឋខ្មែរ ដោយសន្យាតំណែង«ប្រមុខរដ្ឋអស់មួយជីវិត»ដល់គាត់ ។ តើមានចាំទេ មុនពេលស្តេចសីហនុវិលត្រឡប់ទៅស្រុកខ្មែរកាលពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៥ ស្តេចសីហនុបានឆ្វៀលទៅចុះនៅហាណូយមួយអាទិត្យ ដើម្បីសុំភ្លើងខៀវពីយួនឲ្យពិតប្រាកដ អំពីតំណែងរបស់គាត់ជាមុនសិន ទើបគាត់ចុះទៅជាន់ដីស្រុកខ្មែរនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៥ ។

បន្ទាប់ពីបានការព្រមព្រៀងពីស្តេចសីហនុ យួនបានទៅពឹងពាក់បារាំងឲ្យជួយបើកសន្និសីទមួយ ដើម្បីប្រមូលប្រទេសមួយចំនួននិងពួកប្រទេសមហាអំណាចឲ្យមកប្រជុំគ្នាដើម្បីរកដំណោះស្រាយសន្តិភាពឲ្យប្រទេសកម្ពុជា និងជួយកសាងប្រទេសកម្ពុជាឡើងវិញពីភ្នក់ភ្លើងសង្គ្រាម ។ យួនបានពិនិត្យនិងសុខចិត្តឲ្យបារាំងបញ្ចូលមាត្រាមួយចំនួនទៅក្នុងកិច្ចព្រមព្រៀង តែយួនបានគិតរួចជាស្រេចថា ការអនុវត្តន៍តាមកិច្ចព្រមព្រៀងឬមួយក៏អត់ វាអាស្រ័យលើឆន្ទៈរបស់យួនទេតើ ។ មានន័យថា យួនមានចំណងបោកមតិអន្តរជាតិ ជាពិសេសពួកប្រទេសហត្ថលេខីទាំងអស់នោះ ដូចដែលខ្លួនមានពិសោធន៍ធ្លាប់ធ្វើជាមួយអាមេរិកាំងរួចមកហើយកាលសម័យសង្គ្រាមវៀតណាម ។

ប្រតិបត្តិការអ៊ិនតាក់បានបញ្ចប់នៅចុងឆ្នាំ១៩៩៣ ។ តែរឿងមួយដែលយួនភ្ញាក់ស្មៀត គឺគណបក្សហ៊្វុនស៊ិនប៉ិចបានឈ្នះឆ្នោតលើកគណបក្សប្រជាជនកម្ពុជា ។ ម្ល៉ោះហើយយួនត្រូវកែកុនយ៉ាងណា ដើម្បីធ្វើឲ្យហ៊ុន-សែននិងគណបក្សប្រជាជនកម្ពុជាអាចស្ថិតនៅក្នុងអំណាច ។ បើពុំដូច្នោះទេ ផែនការរបស់វាទាំងមូលដែលបានទំថែរក្សាទុករាប់សិបឆ្នាំមកនោះ នឹងត្រូវទទួលនូវបរាជ័យទាំងស្រុង ។ ព្រឹត្តិការណ៍បែងចែកទឹកដីនៅត្រើយខាងកើតទន្លេមេគង្គក៏បានផុសឡើង នៅទន្ទឹមពេលជាមួយគ្នាដែលស្ដេចសីហនុបង្ខំទ្រង់រណឫទ្ធិឲ្យសុខចិត្តបែងចែកអំណាចជាមួយហ៊ុន-សែននិងគណបក្សប្រជាជនកម្ពុជា ។ បើពុំយ៉ាងដូច្នោះទេ ទាំងឪពុកទាំងកូនមុខជាគ្មានបានអ្វីលិទ្ធពុំខាន ។

សូមកុំភ្លេចថា ផែនការរបស់យួនគឺចង់ឲ្យពួកអាយ៉ងរបស់វាក្ដោបក្ដាប់អំណាចពេញទឹងលើស្រុកខ្មែរ ដើម្បីវាងាយស្រួលចាត់ការអនុវត្តសន្ធិសញ្ញាទាំងអស់ដែលវាបានធ្វើ ។ រដ្ឋាភិបាលក្បាលពីរទើងទើង (gouvernement bicéphale) ពុំមែនជាសេចក្ដីប្រាថ្នារបស់យួនទេ តែជាការដោះទ័លមួយដំណាក់កាលប៉ុណ្ណោះ ។ ចំណុចនេះទ្រង់រណឫទ្ធិដឹងខ្លួនពេកណាស់ទៅហើយ ថានៅអាណត្តិទី២ពិតជាត្រូវយួនចំបាក់ពុំខាន ។ ដូច្នេះព្រឹត្តិការណ៍បង្ហូរឈាមឆ្នាំខែកក្កដាឆ្នាំ១៩៩៧ក៏បានកើតឡើង ដែលជាឱកាសយួនក្របែលពួកមេសីហនុនិយម ឬពួកមេហ៊្វុនស៊ិនប៉ិច ដោយកាត់ដៃកាត់ជើងចោលអស់ កុំឲ្យមានអ្វីអាចងើបតតាំងជាមួយពួកវាបានតទៅទៀត ។ ដល់អាណត្តិទី២មកដល់ ក៏ឃើញថាបាក់ស្រុតចុះយ៉ាងដូច្នេះមែន ដោយពួកយួននិងអាយ៉ងគ្រាន់តែបោយដៃឲ្យមកនៅអែបៗជាមួយវា និងឲ្យបានស៊ីពែរខ្លះៗប៉ុណ្ណោះ ។

អាណត្តិទី៣គឺជាអាណត្តិដែលយួននិងពួកអាយ៉ងត្រូវវ៉ៃផ្ដាច់ព្រ័ត ដើម្បីក្ដោបក្ដាប់យករដ្ឋអំណាចទាំងមូល ។ តែនៅក្រោយពេលបោះឆ្នោតឆ្នាំ២០០៣ មានបញ្ហាវាំងស្ទះនយោបាយកើតឡើង ដោយគណបក្សសម-រង្ស៊ីមិនសុខចិត្តទទួលយកលទ្ធផលឆ្នោត ពីព្រោះមានការលួចបន្លំនិងការទិញដូរសន្លឹកឆ្នោតពាសពេញប្រទេសកម្ពុជា ។ ការវាំងស្ទះនេះបានអូសបន្លាយពេលជិតមួយឆ្នាំ ទើបស្ដេចសីហនុលបលួចធ្វើរាជក្រឹត្យមួយ (**រាជក្រឹត្យលេខ នស/រកត/០៧០៥/១១៧ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤**) តែងតាំងហ៊ុន-សែនឲ្យឡើងធ្វើជានាយករដ្ឋមន្ត្រី ។ ដើម្បីជាការតបស្នងសងគុណស្ដេចសីហនុវិញ យួននិងពួកអាយ៉ងបានសុខឲ្យស្ដេចសីហនុផ្ទេររាជ្យទៅឲ្យទ្រង់សីហមុនី ដែលជាសេចក្ដីពេញប្រាថ្នារបស់អ្នកម្នាងម៉ូនិកជាយូរយារណាស់មកហើយ ។

បើគិតរាប់ចាប់ពីពេលអ៊ិនតាក់ចប់បេសកកម្មនៅក្នុងស្រុកខ្មែរឆ្នាំ១៩៩៣មកទល់ឆ្នាំ២០០៥ ដែលយួននិងពួកអាយ៉ងបានសុខចិត្តឲ្យស្ដេចសីហនុផ្ទេររាជ្យទៅកូន ឃើញថា១២ឆ្នាំបានកន្លងផុតទៅហើយ ។ ពួកនិគមជនជាតិយួនក៏បានហូរចូលមកក្នុងស្រុកខ្មែរក៏មានចំនួនយ៉ាងក្រាស់ក្រែល រួមទាំងពួកបូជ្ជិយក្លែងបន្លំខ្លួនចំនួន១០០,០០០ផង (បូជ្ជិយចំនួន១០០,០០០នាក់ដែលកំពុងស្ថិតនៅក្នុងស្រុកខ្មែរនេះ គឺជាសំដីអះអាងចេញពីមាត់របស់ហ៊ុន-សែនផ្ទាល់ ដែលយើងមានអាត់សម្លេងទុកជាឯកសារស្រាប់) ។ ឥឡូវនេះដល់ពេលវេលាល្មមសមគួរហើយ ដែលយួនចង់អនុវត្តសន្ធិសញ្ញាទាំងអស់នោះ ។

តែដើម្បីឲ្យសន្ធិសញ្ញាទាំងអស់នោះរស់រវើកឡើងវិញ យួនត្រូវការឲ្យស្ដេចសីហនុនិងពួកអាយ៉ងប្រឌិតរឿងល្ខោនមួយដើម្បីទាក់ទាញអារម្មណ៍របស់ខ្មែរអំពីរឿងបូណភាពទឹកដី សំរាប់យួនងាយចេញទៅបោះបង្គោល និងដើម្បីឲ្យមានការទទួលស្គាល់ពីសភា, ពីព្រឹទ្ធសភា, ពីរដ្ឋាភិបាល និងជាពិសេសពីស្ដេច ដើម្បីក្ដោបបញ្ចូលការគាំទ្រពីប្រជារាស្ត្រនៅក្នុងពេលតែមួយជាមួយគ្នាតែម្ដង ។ ពោលគឺបានទទួលនូវការព្រមព្រៀងគ្នាទាំងរាស្ត្រ និងទាំងស្ដេច ។

ម្ល៉ោះហើយ គេក៏បានឃើញស្ដេចសីហនុបង្កើតឆាកល្ខោនរឿង «**ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកបញ្ហាព្រំដែន**» ដែលមានខ្លួនគាត់ធ្វើជាប្រធាននិងជាតំណាងព្រះមហាក្សត្រ ។ គាត់ធ្វើជាឈ្លោះគ្នាជាមួយហ៊ុន-សែនមួយសន្ទុះធំ ។ រួចបន្ទាប់មកក៏ចង់សំដែងតួធ្វើជា «**ព្រះយុគន្ធរទី២**» ជិះលើខ្នងដំរីទូលហិប ចេញទៅស្វែងរកមើលបង្គោលព្រំដែនខ្មែរ-យួនពីមួយគីឡូម៉ែត្រម្ដងទៅមួយគីឡូម៉ែត្រម្ដង ។ នៅទីបញ្ចប់ស្រាប់តែគាត់ថ្លែងថា ទាំងអស់ហ្នឹងគឺជា«**រឿងកំប្លុកកំប្លែង**»ទេ ហើយក៏ទម្លាក់វាំងននបិទត្រឹប ដោយប្រកាសលាលែង-លែងលាតែម្ដងទៅ ។ ក៏ប៉ុន្តែលទ្ធផលដែលហូរចេញមកនោះ គឺហ៊ុន-សែនបាននិកាសបង្កើតជា «**សន្ធិសញ្ញាបំពេញបន្ថែម**» សំរាប់ផ្ដល់នូវសុពលភាពទៅលើសន្ធិសញ្ញាឆ្នាំ១៩៨៥ ។ សួរថា តើស្ដេចសីហនុគាត់ប្រឆាំងឬទេ ? មេឃាទៅ ! គឺគាត់ហ្នឹងឯងហើយដែលជាអ្នកទៅបង្ខំឲ្យកូន (ស្ដេចសីហមុនី) ឲ្យចុះហត្ថលេខាទទួលស្គាល់ជា «**ផ្លូវការ**» ។ នេះហើយដែលយួនប្រាថ្នាចង់បានយ៉ាងខ្លាំងជាទីបំផុតនោះ !!

គណៈកម្មាធិការវ៉ា-គីមហុង-យួនក៏បានចាប់ផ្ដើមបង្កើតឡើង ដើម្បីប្រញាប់ប្រញាល់រៀបចំបោះបង្គោលព្រំដែនសាជាថ្មី ។ ពួកគេគ្មានត្រូវការអ្នកជំនាញការផ្សេងឯណាចូលមករំខានការងារនិងផែនការរបស់ពួកគេទេ ។ ពួកគេបាននាំគ្នាចេញអ៊ឹងកងទៅបោះតម្រុយបន្តកន្ទុយគ្នា ចាក់ខែវចូលមកខាងក្នុងដីខ្មែររាប់សិបគីឡូម៉ែត្រ ដោយមិនខ្វល់ពីដីស្រែករដូនតារបស់អ្នកណាឡើយ ។ អាណាយ៉ស្រែកបាត់ដីឯណាក៏យំទៅ ឲ្យតែអញនិងចៅហ្វាយយួនរបស់អញសប្បាយចិត្តបានហើយ ។

រឿងបាត់បង់ដីស្រែរាប់សិបហិកតារបស់ប្រជាពលរដ្ឋខ្មែរនេះម៉្យាង ។ ម៉្យាងទៀត ពេលចុងក្រោយនេះ យួនជាមួយនិងរដ្ឋាភិបាលអាយ៉ងនៅភ្នំពេញមានផែនការបង្កើត«**តំបន់អភិវឌ្ឍន៍មុមបី**» (យួនបីខេត្ត, ខ្មែរបីខេត្ត និងលាវបីខេត្ត) ដែលគ្មានអ្វីក្រៅអំពីការបោះជំហានចេញនៃផែនការ«**សហព័ន្ធឥណ្ឌូចិន**»របស់ហូ-ជីមិញនោះឡើយ ។ បើគេបូកបញ្ចូលជាមួយការបើកច្រកព្រំដែនខ្មែរ-យួនចំហផ្លូងផ្លូវ ដើម្បីឲ្យពួកនិគមជនជាតិយួនរាប់លាននាក់ហូរចូលមកដូចទឹកបាក់ទំនប់ផង ប្រជាពលរដ្ឋខ្មែរដែលនៅសេសសល់ពីស្លាប់ដោយសារស្នាដៃយួន សីហនុ និងប៉ុលពត នឹងក្លាយទៅជាជនជាតិភាគតិចលើមាតុភូមិកំណើតរបស់ខ្លួននាពេលឆាប់ៗខាងមុខនេះជាមិនខានឡើយ ។ ផែនការមួយថ្មីទៀតរបស់ពួកយួននិងអាយ៉ង គឺគេវាស់ដីខ្មែរនៅតាមបណ្ដោយព្រំដែន រាប់ចាប់ពីខេត្តនៅខាងក្រោមឡើងទៅទល់នឹងខេត្តព្រះវិហារ ដាក់ធ្វើសម្បទានឲ្យយួនចូលមកប្រកបរបរដាំដើមកៅស៊ូរាប់ម៉ឺនហិកតាក្នុងរយៈពេលជាង៩០ឆ្នាំ ។ ការធ្វើសម្បទានដីធ្លីទាំងអស់នេះ គឺគ្មានអ្វីក្រៅអំពីផ្ដល់លេសឲ្យយួនហូរចូលមកស្រុកខ្មែរ និងធ្វើជាម្ចាស់ដីនៅតាមទីកន្លែងនោះដោយស្របច្បាប់ឡើយ ។ នេះហើយជាគំនិតក្បត់ជាតិរបស់ស្ដេចសីហនុ និងពួកអាយ៉ងយួននៅភ្នំពេញ ដែលមានហ៊ុន-សែនជាមេក្លោង ។៚

❑